ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / 12 / 2012
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ព្រហស្បត្តិ៍ ទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី- ថ្ងៃទី ១៣២

រៀបចំដោយ: សែ កុលវុឌ្ឍី និង Roger PHILLIPS

| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក Roger PHILLIPS, |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក ចាន់ ដារារស្មី, លោក Vincent de WILDE D'ESTMAEL, លោក Keith RAYNOR. |
| ជនជាប់ចោទ៖ នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Andrew IANUZZI. |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS. |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE. |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Elisabeth SIMONNEAU-FORT, លោក វ៉ែន ពៅ, លោកស្រី ម៉ុច សុវណ្ណារី, លោកស្រី Christine MARTINEAU, លោក ឡៅ ជុនធី, លោក ហុង គីមសួន, លោកស្រី ទី ស្រីនណា. |
| សាក្សី/ដើមបណ្តឹងរដ្ឋប្បវេណី៖ លោក មាស សារ៉ាន (TCCP-82), លោកស្រី អោ រី (TCCP-105) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី ស្ល សុផ្លារី |
| ផ្សេងៗ៖ កញ្ញា Eleanor DOYLE-MARKWICK. |

**<u>ពេលវេលាទូទៅរបស់តុលាការ៖</u>**

| ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.២៥ | បញ្ចប់ម៉ោង៖ ១៦.០៥ |
|---|---|---|
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៤៥ | បញ្ចប់ម៉ោង៖ ១១.០៥ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣៥ |
| សម្រាកពេលល្ងាច | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០៥ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៤ ម៉ោង និង ២៥ នាទី | | |

**<u>កិច្ចដំណើរការនីតិវិធី៖</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ដំណើរការសវនាការបានចាប់ផ្តើមនៅម៉ោង ៩.២៥ នាទី ដោយបញ្ហាបច្ចេកទេស | | | |
| ការស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ | មេធាវីការពារក្តី អៀង សារី<br><br>មេធាវីការពារក្តី នួន ជា | ០៩.២៦<br>១៥.១២<br>១០.៤៤ | ០៩.២៧<br>១៥.១៣<br>១១.០៧ |
| អវត្តមានមេធាវីអន្តរជាតិការពារក្តី អៀង សារី | អង្គជំនុំជម្រះ | ០៩.២៧ | ០៩.២៧ |
| ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ (TCCP-82) | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ០៩.២៨ | ១០.១២ |

| | | | |
|---|---|---|---|
| | សហព្រះរាជអាជ្ញា<br>អង្គជំនុំជម្រះ<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី ខៀវ សំផន | ១០.១២<br>១១.២៦<br>១១.៣៦<br>១៤.៣១<br>១៤.៣២ | ១១.២៦<br>១១.៣៥<br>១៤.៣០<br>១៤.៣២<br>១៤.៣២ |
| ការថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន (TCCP-82) | អង្គជំនុំជម្រះ | ១៤.៣៣ | ១៤.៣៧ |
| សេចក្តីសម្រេចលើវិធីសាស្ត្រនៃការតាំងសំណួរទៅសាក្សី | អង្គជំនុំជម្រះ | ១១.៥៨ | ១២.០៤ |
| ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី អោ រី (TCCP-105) | អង្គជំនុំជម្រះ<br>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ១៥.១៣<br>១៥.១៨ | ១៥.១៧<br>១៦.០៤ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

ដោយសារមានបញ្ហាបច្ចេកទេស អង្គជំនុំជម្រះបានពន្យារពេលសវនាការរហូតដល់ម៉ោង ៩.២៥។

**<u>ការស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ</u>**

ជនជាប់ចោទ អៀង សារី បានលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការក្នុងអំឡុងពេលនៃការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី TCCP-82 និង TCCP-105 ។

ជនជាប់ចោទ នួន ជា តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការសម្រាប់រយៈពេលពេញមួយថ្ងៃដោយសារមូលហេតុសុខភាព។ គ្រូពេទ្យព្យាបាល បានពិនិត្យជនជាប់ចោទ នួន ជា នៅក្នុងអំឡុងពេលសម្រាក បន្ទាប់ពីទទួលបានរបាយការណ៍ពេទ្យ អង្គជំនុំជម្រះបានសម្រេចឱ្យ នួន ជា តាមដានដំណើរការសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោម សាលសវនាការ។

**<u>អវត្តមានមេធាវីអន្តរជាតិការពារក្តី អៀង សារី</u>**

មេធាវីអន្តរជាតិការពារក្តី អៀង សារី លោក Karnavas បានអវត្តមានពីដំណើរការសវនាការដោយមូល

ហេតុផ្ទាល់ខ្លួន។

**ការបន្តតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី មាស សាវ៉ាន** (TCCP-82)

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបន្តតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី មាស សាវ៉ាន បន្ទាប់មក សហព្រះរាជអាជ្ញា អង្គជំនុំជម្រះ និងមេធាវីការពារក្តី នួន ជា បានតាំងសំណួរទៅដើមបណ្តឹង មាសសាវ៉ាន។ មេធាវីការពារក្តី អៀង សារី និង ខៀវ សំផន បានបញ្ជាក់ថាពួកគេមិនមានសំណួរក្នុងការសួរទៅដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទេ។ ជាចុងក្រោយ ដើមបណ្តឹងរដ្ឋប្បវេណី មាស សាវ៉ាន បានធ្វើសេចក្តីថ្លែងអំពីទុក្ខសោក និងព្យសនកម្មផ្សេងៗដែលគាត់បានទទួលរងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។

**សេចក្តីសម្រេចលើការជំទាស់របស់សហព្រះរាជអាជ្ញា**

សហព្រះរាជអាជ្ញា បានជំទាស់ចំពោះការតាំងសំណួរដោយមេធាវីការពារក្តី នួន ជា ក្នុងការណែនាំឱ្យសាក្សីឆ្លើយទៅនឹងសំណួររបស់ខ្លួន។

សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ៖ ទី១ ទីនេះគឺប្រភពច្បាប់ ដែលអនុវត្តច្បាប់ស៊ីវិលឡូ។ ទី២ សំណួរបែបនាំមុខអង្គជំនុំជម្រះបានហាមឃាត់ភាគីទាំងអស់នៃរឿងក្តីមិនឱ្យប្រើប្រាស់សំណួរប្រភេទនេះតាំងពីដើមទីមក។ ទី៣ សំណួរដែលភាគីធ្វើសេចក្តីសន្និដ្ឋានខ្លួនឯង ឱ្យដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សីវាយតម្លៃលើសេចក្តីសន្និដ្ឋានរបស់ភាគី អង្គជំនុំជម្រះបានហាមឃាត់តាំងពីដើមដំបូងមក។ នីតិវិធីបែបស៊ីវិលឡូ មិនអនុញ្ញាតឱ្យធ្វើដូច្នេះទេ។ ទីនេះគឺអនុវត្តផងដែរ ហើយជាអតិបរមានូវច្បាប់កម្ពុជា តាមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋកម្ពុជា ក៏ដូចជាច្បាប់ អ.វ.ត.ក ហើយវិធានផ្ទៃក្នុងក៏បានសម្របសម្រួលឱ្យសមស្របទៅនឹងកិច្ចព្រមព្រៀង និងច្បាប់គោលជាមូលដ្ឋានដែលអនុវត្តនៅទីនេះដែរ។

**ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី សោ វី** (TCCP-105)

ប្រធានអង្គជំនុំជម្រះបានតាំងសំណួរបឋមមួយចំនួនទាក់ទងនឹងប្រវត្តិសាវតារបស់ដើមបណ្តឹងរដ្ឋប្បវេណី បន្ទាប់មកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៩៧ (៣) វិធាននៃវិធានផ្ទៃក្នុង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/3966 | D22/118 | 00362173-00362183 00362194-00362201 00362202-00362209 | ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លោក មាស សារ៉ាន់<br>Civil party application of Mr. MEAS Saran<br>Demande de constitution de partie civile de M. MEAS Saran | P | 00362176 | 00362196 | 00362204 |
| E3/1757 | D222/1.17 | 00710225-00710230, 00789169-00789258 00396894-00397284 00700095-00700099, 00763550-00763601 | សៀវភៅរៀបរៀងដោយ VICKERY Michael, Cambodia 1975-1982 ប្រទេសកម្ពុជា ឆ្នាំ១៩៧៥-១៩៨២<br>Book by VICKERY Michael, Cambodia 1975-1982<br>Book by VICKERY Michael, Cambodia 1975-1982 | P | | 00396999 | |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតិឲ្យជនជាប់ចោទ នួន ជា (១១.០៨) ចូលរួមដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់ឃុំខ្លួន (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។
- បង្គាប់ឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូន ដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន (TCCP-82) ត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់វិញ។
- បង្គាប់ឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូន ដើមបណ្តឹងរដ្ឋប្បវេណី អោ រី (TCCP-105) ត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅរបស់គាត់ និងឲ្យនាំគាត់ត្រឡប់មកកាន់បន្ទប់សវនាការនៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២។
- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំគាត់មកកាន់បន្ទប់សវនាការនៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ។

| **<u>កាលបរិច្ឆេទបន្តសវនាការ៖</u>** |
|---|
| **សវនាការនឹងបន្តទៅថ្ងៃ សុក្រ ទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។** |

**ភ្នំពេញ ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២**

**ក្រឡាបញ្ជី**

**សែ** [illegible] / Roger PHILLIPS